## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា ក្រសួងបានបន្តសម្របសម្រួលវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ ស្របតាមតួនាទីដែលមានចែងក្នុងច្បាប់ជាធរមាន ក៏ដូចជាស្របតាមស្មារតីចង់បានរបស់តំណាងភាគីកម្មករនិយោជិតដែលចង់ជួបចរចាជាមួយក្រុមហ៊ុនផ្ទាល់។ នៅរសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ នេះ ក្រសួងបានបន្តអញ្ជើញគូភាគីវិវាទមកជួបប្រជុំដោះស្រាយជាលើកទី៤ ក្រោមអធិបតីភាពរបស់ឯកឧត្តម ទេស រុក្ខាផល អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ក.ប. ដោយមានតំណាងភាគីកម្មករនិយោជិត រួមមាន លោកស្រី ឈឹម ស៊ីថរ, លោកស្រី ឈឹម សុខន, លោកស្រី វី សុវណ្ណឌី, លោកស្រី សុន ស្រីពេជ្រ, លោកស្រី ហៃ សុភាព និងតំណាងនិយោជក រួមមានលោក Hein Dames, លោក ហយ វលាភ, លោកស្រី ឌី សីហា, លោកស្រី រស់ ប៊ុនឡេង និងលោកស្រី ចន្ទ រក្សា ដោយភាគីទាំងពីរបានលើកឡើងនូវមតិយោបល់ ដូចខាងក្រោម៖

**សហជីព និងតំណាងកម្មករនិយោជិត៖**

១.ស្នើឱ្យលើកយកចំណុចទាមទារយកចូលធ្វើការវិញ មកពិភាក្សាមុននឹងឈានទៅពិភាក្សាចំណុចវិវាទផ្សេងទៀត ដោយស្នើឱ្យនិយោជកផ្តល់ចម្លើយតបចំពោះការទាមទារនេះ។ ប្រសិនបើភាគីនិយោជកមិនព្រមយកចំណុចនេះមកពិភាក្សាគ្នាទេ នឹងនាំឱ្យការចរចានេះ ជាប់គាំងបន្តទៀត។

២.រហូតមកដល់ពេលនេះ នៅសល់កម្មករនិយោជិតប្រហែល ២០០នាក់ ដែលបន្តទាមទារយកចូលធ្វើការវិញ។

៣.រហូតមកដល់ពេលនេះ មានកម្មករនិយោជិតដែលកំពុងធ្វើការប្រហែល ៣០០នាក់ យល់ព្រមលាឈប់ពីការងារ ដើម្បីធ្វើការដោះដូរជាមួយកម្មករនិយោជិតប្រហែល ២០០នាក់ ដែលទាមទារចូលធ្វើការវិញ។ ជម្រើសនេះ អាចឱ្យនិយោជកសម្រេចគម្រោងកាត់បន្ថយបុគ្គលិករបស់ខ្លួនផង និងអាចឱ្យកម្មករនិយោជិតដែលទាមទារចូលធ្វើការវិញ អាចចូលធ្វើការវិញផងដែរ។ ដូច្នេះ ស្នើឱ្យភាគីនិយោជកពិចារណាអំពីជម្រើសនៃការដោះដូរកម្មករនិយោជិតនេះ។

៤.មានការសោកស្តាយ ដែលភាគីនិយោជកមិនជជែកពីជម្រើសនៃដំណោះស្រាយនៃការដោះដូរ។ តំណាងកម្មករនិយោជិត នឹងបន្តដាក់សំណើនេះជាលាយលក្ខណ៍អក្សរទៅភាគីនិយោជក ដើម្បីទទួលបានចម្លើយបន្ថែមទៀត។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

៥. ប្រសិនបើភាគីនិយោជកមិនមានដំណោះស្រាយទៅនឹងសំណើដោះដូរទេ ភាគីតំណាងកម្មករនិយោជិត នឹងមិនអាចមកចូលរួមប្រជុំបន្តទៀតទេ។

**តំណាងក្រុមហ៊ុន ណាហ្គាវើលដ៏៖**

១. ស្នើលើកយកចំណុចវិវាទទី៣ និងទី៤ នៃសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ០១២/២១ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ មកជជែកជាមុន ដែលវានឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់បុគ្គលិកភាគច្រើន ជាជាងចំណុចទី១ ដែលពាក់ព័ន្ធតែក្រុមបុគ្គលិកមួយចំនួនតូច។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិតនៅតែបន្តលើកយកចំណុចវិវាទទី១ មកពិភាក្សាមុន ភាគីនិយោជកយល់ព្រមពិភាក្សា។

២.ក្នុងគម្រោងរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុង ក្រុមហ៊ុនបានត្រួតពិនិត្យអំពីលក្ខខណ្ឌជាច្រើននិងជាក់លាក់ ហើយក្រុមហ៊ុនប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេច ដោយឆ្លងកាត់ការប្រឹក្សាយោបល់តាមច្បាប់ស្តីពីការងារ។ រីឯការលើកឡើងរបស់ភាគីតំណាងកម្មករនិយោជិត មានន័យហាក់ដូចជាសហជីពចង់ដើរតួជាអ្នកទទួលខុសត្រូវអំពីដំណើរការអាជីវកម្មជំនួសក្រុមហ៊ុនទៅវិញ។

៣.បច្ចុប្បន្ននេះ មានកម្មករនិយោជិតដែលកំពុងបម្រើការងារប្រហែល ៦០០នាក់ នៅតែជាចំនួនដែលលើសពីតម្រូវការជាក់ស្តែង។ ដូចនេះ ប្រសិនបើអ្នកទាំង ៣០០នាក់ ដែលចង់លាឈប់នោះ អាចសម្រេចចិត្តដាក់ពាក្យលាឈប់បាន ហើយក្រុមហ៊ុននឹងទូទាត់ប្រាក់បំណាច់តាមការលាឈប់ពីការងារដោយស្ម័គ្រចិត្ត។ ដូច្នេះហើយ ទើបភាគីនិយោជកនៅតែចង់លើកយកចំណុចផ្សេងទៀត ដែលមានក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមកពិភាក្សា ព្រោះវាមានអត្ថប្រយោជន៍មិនត្រឹមតែចំពោះកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ទេ តែក៏មានអត្ថប្រយោជន៍ចំពោះកម្មករនិយោជិតដែលកំពុងធ្វើការផងដែរ។

៤.ជម្រើសនៃការដោះដូររវាងកម្មករនិយោជិតដែលចង់លាឈប់ពីការងារ និងកម្មករនិយោជិតដែលទាមទារចូលធ្វើការវិញ គឺភាគីនិយោជកនឹងមិនពិចារណាទេ។

ក្រោយពីការពិភាក្សាគ្នាយ៉ាងផុសផុល និងការធ្វើបទបង្ហាញអំពីទិដ្ឋភាពច្បាប់ពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងាររបស់អធិការការងារ ភាគីទាំងពីរបានឯកភាពគ្នាកំណត់កាលបរិច្ឆេទប្រជុំបន្ទាប់នៅថ្ងៃពុធ ទី២៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៤:៣០នាទី។

បើទោះបីជាមិនទាន់មានការឯកភាពគ្នា ក៏ក្រសួងនឹងបន្តធ្វើការសម្របសម្រួល និងកំណត់កាលបរិច្ឆេទប្រជុំបន្តបន្ទាប់ទៀត ស្របតាមតួនាទីដែលកំណត់ដោយច្បាប់ ក៏ដូចជាការទាមទាររបស់គូភាគី។

ជាថ្មីម្តងទៀត ក្រសួងស្នើឱ្យភាគីទាំងពីរមានការយោគយល់គ្នាខ្ពស់ក្នុងការចូលរួមដោះស្រាយបញ្ចប់វិវាទការងារនេះ, បន្តសហការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធដោយសន្តិវិធី, និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ យោងតាមនីតិវិធីច្បាប់ ប្រសិនបើការចរចានៅតែមិនអាចមានដំណោះស្រាយបាននីតិវិធីបន្ទាប់ គឺភាគីទាំងពីរអាចដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីរកដំណោះស្រាយចុងក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២